## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ......សហវ.

# ប្រកាស
# ស្តីពី
# ពន្ធលើអចលនទ្រព្យ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥២៣/០០៤ ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១ ._**

ប្រកាសនេះ មានគោលបំណងកំណត់នូវវិធាននិងនីតិវិធីនៃការគ្រប់គ្រងប្រមូលពន្ធលើអចលនទ្រព្យ។

**ប្រការ២ ._**

ប្រកាសនេះ មានវិសាលភាពអនុវត្តលើអចលនទ្រព្យដែលស្ថិតនៅក្នុងរដ្ឋបាលរាជធានី ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៣ ._**

សម្រាប់គោលដៅនៃប្រកាសនេះ៖

១- អចលនទ្រព្យ សំដៅដល់៖

ក- ដីគ្មានសំណង់ និង/ឬដីមានសំណង់។

ខ- ផ្ទះ ឬទីកន្លែងសម្រាប់ស្នាក់នៅដទៃទៀត។

គ- អគារ ឬសំណង់ផ្សេងៗ ទោះមានឬគ្មានជញ្ជាំងឬដំបូលក៏ដោយ មានជាអាទិ៍ សណ្ឋាគារ អផាតមែន ខុនដូ ឬអគារសហកម្មសិទ្ធិ ការិយាល័យ រោងចក្រ ឃ្លាំង ផ្សារ សំណង់អគារឧស្សាហកម្ម ផ្លូវ ស្ពាន ប្រព័ន្ធផលិតទឹកស្អាតឬផលិតអគ្គិសនី ព្រលានយន្តហោះ កំពង់ផែ ចំណតរថយន្ត។

២- អ្នកជាប់ពន្ធ សំដៅដល់ រូបវន្តបុគ្គលឬនីតិបុគ្គល ដែលជាកម្មសិទ្ធិករឬអ្នកកាន់កាប់ឬអ្នកទទួលប្រយោជន៍ចុងក្រោយនៃអចលនទ្រព្យដូចមានចែងក្នុងកថាខណ្ឌទី១ នៃប្រការនេះ រួមមាន៖

ក- កម្មសិទ្ធិករ ដែលមានបណ្ណសម្គាល់សិទ្ធិឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលចេញដោយរដ្ឋបាលសុរិយោដី។

ខ- អ្នកកាន់កាប់ ដែលគ្មានបណ្ណសម្គាល់សិទ្ធិឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលចេញដោយរដ្ឋបាលសុរិយោដី។

គ- អ្នកទទួលប្រយោជន៍ចុងក្រោយនៃអចលនទ្រព្យ ដែលទទួលនូវសិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល សិទ្ធិចាត់ចែង និងសិទ្ធិអាស្រ័យនៅ។

**ប្រការ៤ ._**

ពន្ធលើអចលនទ្រព្យ ត្រូវបានប្រមូលប្រចាំឆ្នាំតាមអត្រា ០,១ (សូន្យក្បៀសមួយ) ភាគរយ នៃមូលដ្ឋានគិតពន្ធ។

**ប្រការ៥ ._**

មូលដ្ឋានគិតពន្ធលើអចលនទ្រព្យ ត្រូវផ្អែកលើតម្លៃអចលនទ្រព្យដែលកំណត់ដោយគណៈកម្មការវាយតម្លៃអចលនទ្រព្យសម្រាប់ពន្ធលើអចលនទ្រព្យ ដោយត្រូវបានអនុញ្ញាតឱ្យកាត់បន្ថយនូវទឹកប្រាក់ចំនួន ១០០ ០០០ ០០០ (មួយរយលាន) រៀល។

**ប្រការ៦ ._**

ការចុះបញ្ជីអចលនទ្រព្យ និងកាតព្វកិច្ចរបស់អ្នកជាប់ពន្ធ ត្រូវបានកំណត់ដូចខាងក្រោម៖

១- អ្នកជាប់ពន្ធត្រូវចុះបញ្ជីអចលនទ្រព្យនៅរដ្ឋបាលសារពើពន្ធ ដោយត្រូវបំពេញទម្រង់ចុះបញ្ជីដែលរដ្ឋបាលសារពើពន្ធបានកំណត់ និងភ្ជាប់មកជាមួយនូវឯកសារថតចម្លង ដូចខាងក្រោម៖

ក- ឯកសារកំណត់អត្តសញ្ញាណកម្មរបស់អ្នកជាប់ពន្ធ៖

- រូបវន្តបុគ្គល៖ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរឬសំបុត្របញ្ជាក់កំណើតឬលិខិតឆ្លងដែនសម្រាប់ជនបរទេស
- នីតិបុគ្គល៖ វិញ្ញាបនបត្រចុះបញ្ជីពន្ធដារឬប័ណ្ណពន្ធប៉ាតង់។



4

ខ- សៀវភៅគ្រួសារឬសៀវភៅស្នាក់នៅឬលិខិតបញ្ជាក់ទីលំនៅ (ប្រសិនបើមាន)។

គ- បណ្ណសម្គាល់កម្មសិទ្ធិឬបណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុឬវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលចេញដោយរដ្ឋបាលសុរិយោដីឬឯកសារពាក់ព័ន្ធនឹងការកាន់កាប់អចលនទ្រព្យ ដែលបញ្ជាក់ដោយអាជ្ញាធរឃុំ/សង្កាត់ឡើងទៅ។

ឃ- រូបថតនិងទីតាំងអចលនទ្រព្យ (និយាមកា)។

អចលនទ្រព្យដែលបានចុះបញ្ជីរួចហើយ ត្រូវទទួលបានលេខអត្តសញ្ញាណកម្មសម្គាល់អចលនទ្រព្យ សម្រាប់ប្រើប្រាស់លើឯកសារទាក់ទិននឹងអចលនទ្រព្យនោះ។

២-អ្នកជាប់ពន្ធ ត្រូវផ្តល់ព័ត៌មានជូនរដ្ឋបាលសារពើពន្ធទៅតាមទម្រង់ដែលបានកំណត់ដោយរដ្ឋបាលសារពើពន្ធក្នុងករណីដូចខាងក្រោម៖

ក- អចលនទ្រព្យ ត្រូវបានប្រែប្រួលដូចខាងក្រោម៖

- ដីត្រូវបានយកទៅសាងសង់ផ្ទះ អគារ និង/ឬសំណង់ផ្សេងៗ
- ផ្ទះ អគារ ឬសំណង់ផ្សេងៗ ត្រូវបានសង់បន្ថែមឬបន្ថយឬរំលាយចោល។

ខ- អចលនទ្រព្យ ត្រូវបានផ្លាស់ប្តូរកម្មសិទ្ធិករឬអ្នកកាន់កាប់ឬអ្នកទទួលប្រយោជន៍ចុងក្រោយ។

គ- អចលនទ្រព្យ ត្រូវបានបំបែកឬបង្រួមក្បាលដី។

៣-រដ្ឋបាលសារពើពន្ធត្រូវអនុវត្តការចុះបញ្ជីនិងប្រមូលពន្ធលើអចលនទ្រព្យតាមរាជធានី ខេត្ត តាមការកំណត់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៧ ._**

ពន្ធលើអចលនទ្រព្យ ត្រូវបានលើកលែងដូចខាងក្រោម៖

១-អចលនទ្រព្យដែលមានតម្លៃតិចជាងឬស្មើ ១០០ ០០០ ០០០ (មួយរយលាន) រៀល។

២-អចលនទ្រព្យដែលជាដីកសិកម្ម។ ដីកសិកម្ម សំដៅដល់ ដីដែលកំពុងបង្កបង្កើនផលកសិកម្ម មានជាអាទិ៍ ដីស្រែ ដីចំការ ដីដំណាំកសិឧស្សាហកម្ម ដីកសិដ្ឋានចិញ្ចឹមសត្វ វារីវប្បកម្ម និងដីស្រែអំបិល។ ផ្ទះ អគារ ឬសំណង់ផ្សេងៗដែលសាងសង់សម្រាប់បម្រើផ្ទាល់និងជាអចិន្ត្រៃយ៍ដល់សកម្មភាពកសិកម្មទាំងនេះ ក៏ត្រូវបានលើកលែងពន្ធផងដែរ។ ក្នុងករណីចំណែកណាមួយនៃដីកសិកម្មត្រូវបានយកមកសាងសង់ផ្ទះ អគារ ឬសំណង់ផ្សេងៗ ដែលមិនបម្រើផ្ទាល់និងជាអចិន្ត្រៃយ៍ដល់សកម្មភាពកសិកម្ម ចំណែកដីនេះមិនត្រូវបានលើកលែងពន្ធនេះទេ។

៣-អចលនទ្រព្យដែលជាកម្មសិទ្ធិរបស់រាជរដ្ឋាភិបាល ឬស្ថាប័នរាជរដ្ឋាភិបាល វៀរលែងតែអចលនទ្រព្យដែលបានកត់ត្រាជាទ្រព្យសកម្មរបស់សហគ្រាសសាធារណៈឬក្រុមហ៊ុនចម្រុះរដ្ឋ។

៤-អចលនទ្រព្យដែលជាដីកម្មសិទ្ធិរបស់រាជរដ្ឋាភិបាល ឬស្ថាប័នរាជរដ្ឋាភិបាល បានជួលឱ្យឯកជនសាងសង់សំណង់សម្រាប់ធ្វើអាជីវកម្ម ដីនោះត្រូវបានលើកលែងពន្ធលើអចលនទ្រព្យ ប៉ុន្តែសំណង់ត្រូវជាប់ពន្ធ។

៥-អចលនទ្រព្យដែលជាកម្មសិទ្ធិបុគ្គលណាមួយ ដែលត្រូវបានរៀបចំឡើងនិងដំណើរការសម្រាប់គោលដៅសុទ្ធសាធខាងសាសនានិងសប្បុរសធម៌ និងគ្មានចំណែកណាមួយនៃអចលនទ្រព្យឬប្រាក់ចំណូលត្រូវបានប្រើប្រាស់ជាប្រយោជន៍ឯកជន។ ការលើកលែងដូចមានចែងក្នុងកថាខណ្ឌនេះ មិនរាប់បញ្ចូលទេ ចំពោះ៖

ក- អចលនទ្រព្យដែលត្រូវបានជួលឬផ្តល់ឱ្យបណ្តោះអាសន្ន សម្រាប់គោលដៅសុទ្ធសាធខាងសាសនា និងសប្បុរសធម៌។

ខ- អចលនទ្រព្យជាកម្មសិទ្ធិរបស់អង្គការសាសនាឬអង្គការសប្បុរសធម៌ ដែលបានជួលឬផ្តល់ជាបណ្តោះអាសន្នឱ្យទៅសហគមន៍ឬបុគ្គលណាមួយ ដែលប្រើប្រាស់អចលនទ្រព្យនោះក្រៅពីគោលដៅសុទ្ធសាធខាងសាសនា និងសប្បុរសធម៌។



ᒪ

៦-អចលនទ្រព្យជាកម្មសិទ្ធិរបស់បេសកកម្មការទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ដែលទទួលស្គាល់ដោយរាជរដ្ឋាភិបាល។ ការលើកលែងដូចមានចែងក្នុងកថាខណ្ឌនេះ មិនរាប់បញ្ចូលទេ ចំពោះ៖

ក- អចលនទ្រព្យជាកម្មសិទ្ធិរបស់បុគ្គលណាមួយដែលបានជួលទៅឱ្យបេសកកម្មការទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា។

ខ- អចលនទ្រព្យជាកម្មសិទ្ធិរបស់បេសកកម្មការទូតឬកុងស៊ុលបរទេស អង្គការអន្តរជាតិ និងទីភ្នាក់ងារសហប្រតិបត្តិការបច្ចេកទេសរបស់រដ្ឋាភិបាលនានា ដែលបានជួលទៅឱ្យបុគ្គលដទៃ។

៧-អចលនទ្រព្យ ដែលជាហេដ្ឋារចនាសម្ព័ន្ធ រួមមាន ផ្លូវ ស្ពាន ប្រព័ន្ធផលិតទឹកស្អាតឬផលិតអគ្គិសនី ទីលានទុកដាក់សំរាម ព្រលានយន្តហោះ កំពង់ផែ ស្ថានីយអយស្ម័យយាន រួមបញ្ចូលទាំងអគារ និងការិយាល័យដែលបម្រើផ្ទាល់ដល់សកម្មភាពនៃហេដ្ឋារចនាសម្ព័ន្ធទាំងនោះ។

៨-អចលនទ្រព្យដែលទទួលរងនូវការខូចខាតធ្ងន់ធ្ងរដោយករណីប្រធានស័ក្តិ ដែលជាបាតុភូត ឬជាព្រឹត្តិការណ៍កើតឡើងដោយមិនដឹងជាមុន មិនអាចប៉ាន់ស្មានជាមុនបាន និងមិនអាចជម្នះបាន ដូចជា គ្រោះធម្មជាតិ សង្គ្រាម កុបកម្ម អគ្គិភ័យ ឬគ្រោះមហន្តរាយជាយថាហេតុ។

៩-ផ្ទះ អគារ ឬសំណង់ដែលកំពុងត្រូវបានសាងសង់តិចជាង ៨០ (ប៉ែតសិប) ភាគរយ និងមិនទាន់បានប្រើប្រាស់ វៀរលែងតែដីដែលត្រូវជាប់ពន្ធលើអចលនទ្រព្យ។

១០-អចលនទ្រព្យដែលស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស ដែលបម្រើផ្ទាល់ដល់សកម្មភាពផលិតកម្មនិងសេវាកម្ម។

**ប្រការ៨ .-**

អ្នកជាប់ពន្ធ ត្រូវមានសិទ្ធិនិងកាតព្វកិច្ចដូចខាងក្រោម៖

១-ចំពោះអចលនទ្រព្យដែលមានតម្លៃ ១០០ ០០០ ០០០ (មួយរយលាន) រៀល ឬតិចជាង អ្នកជាប់ពន្ធមិនមានកាតព្វកិច្ចដាក់លិខិតប្រកាសសារពើពន្ធនិងបង់ប្រាក់ពន្ធលើអចលនទ្រព្យទេ។

២-ចំពោះអចលនទ្រព្យដែលមានតម្លៃលើសពី ១០០ ០០០ ០០០ (មួយរយលាន) រៀល ត្រូវដាក់លិខិតប្រកាសសារពើពន្ធនិងបង់ប្រាក់ពន្ធលើអចលនទ្រព្យជូនរដ្ឋបាលសារពើពន្ធ យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែកញ្ញា ជារៀងរាល់ឆ្នាំ។

៣-ចំពោះអចលនទ្រព្យ (មានបណ្ណកម្មសិទ្ធិ ឬគ្មានបណ្ណកម្មសិទ្ធិ) ដែលពុំធ្លាប់បានចុះបញ្ជីនិងប្រកាសបង់ពន្ធលើអចលនទ្រព្យកន្លងមក អនុញ្ញាតឱ្យចុះបញ្ជីនិងបង់ពន្ធចាប់ពីឆ្នាំកាន់កាប់ឬអាស្រ័យផលឬទទួលប្រយោជន៍ចុងក្រោយ។

៤-អ្នកជាប់ពន្ធអាចធ្វើការផ្ទេរសិទ្ធិឱ្យបុគ្គលណាមួយឬតំណាងបំពេញកាតព្វកិច្ចពាក់ព័ន្ធនឹងពន្ធលើអចលនទ្រព្យជំនួសខ្លួន។ អ្នកជាប់ពន្ធត្រូវទទួលខុសត្រូវចំពោះបទប្បញ្ញត្តិពាក់ព័ន្ធនឹងពន្ធលើអចលនទ្រព្យនូវរាល់សកម្មភាពរបស់បុគ្គលទទួលការផ្ទេរសិទ្ធិឬតំណាង។

**ប្រការ៩ .-**

រដ្ឋបាលសារពើពន្ធ មានសិទ្ធិអំណាចពិនិត្យលើអចលនទ្រព្យរបស់អ្នកជាប់ពន្ធដែល៖

១-មិនបានចុះបញ្ជីអចលនទ្រព្យដែលមានតម្លៃលើសពី ១០០ ០០០ ០០០ (មួយរយលាន) រៀល។

២-មិនបានដាក់លិខិតប្រកាសសារពើពន្ធ និង/ឬបង់ប្រាក់ពន្ធលើអចលនទ្រព្យតាមកាលកំណត់។

៣-ប្រកាសបង់ពន្ធមិនបានត្រឹមត្រូវនូវមូលដ្ឋានគិតពន្ធលើអចលនទ្រព្យ។

៤-អចលនទ្រព្យដូចមានចែងក្នុងប្រការ៧ នៃប្រកាសនេះ។

**ប្រការ១០ ._**

ប្រកាសនេះ មិនមានអានុភាពប្រតិសកម្មចំពោះប្រាក់ពន្ធ ពន្ធបន្ថែម និងការប្រាក់ដែលបានបង់រួច។

**ប្រការ១១ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១២ ._**

រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋាន ឬអគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ តទៅ។

ថ្ងៃព្រហស្បតិ៍ ៤រោច ខែមិគសិរ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី-ខេត្ត
- ដូចប្រការ១២ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ